ឆ្នាំ LCAP ☐ 2017–18 ☒ 2018–19 ☐ 2019–20

# គំរូផែនការគ្រប់គ្រងនិងទំនួលខុសត្រូវរបស់ក្រសួងអប់រំនិងកំណែតម្រូវប្រចាំឆ្នាំ

កំណែបន្ថែម: ការណែនាំទូទៅនិងតម្រូវការនិយតកម្ម

ឧបសម្ព័ន្ធ A: អត្រានៃការគណនាលើអាទិភាព 5 និង 6

ឧបសម្ព័ន្ធ B: សំណួរនាំមុខ: ប្រើសម្រាប់ផ្តើម(ពុំមានកំរិតទេ)

រង្វាស់ស្តង់ប្រមាណ LCFF Evaluation Rubrics [ កំណត់សម្គាល់: ឯកសារនេះមានភ្ជាប់ទៅនឹងគេហទំព័រខ្នាតគំរូស្តង់ប្រមាណ LCFF នៅពេលណាគេបានដាក់បញ្ចូល ]: ទិន្នន័យសំខាន់ដើម្បីគាំទ្រដល់ការរៀបចំ LCAP នេះ។ សូមធ្វើការវិភាគមើលទិន្នន័យពេញលេញរបស់ LEA ហើយបណ្តាញបន្តភ្ជាប់ទៅនឹងរង្វាស់ក៏មានផ្តល់ឲ្យដែរនៅក្នុងគំរូ។

| | | | |
|---|---|---|---|
| ឈ្មោះក្រសួងអប់រំ | Long Beach Unified School District (LBUSD) | | |
| ឈ្មោះនិងមុខងារអ្នកធ្វើទំនាក់ទំនង | Christopher J. Steinhauser<br>អគ្គនាយកសាលារៀន | អ៊ីមែលនិងទូរស័ព្ទ | cstein@lbschools.net<br>562-997-8242 |

## សេចក្តីសង្ខេបផែនការឆ្នាំ 2017-20

### ប្រវត្ត

ការពណ៌នាជាសង្ខេបអំពីសិស្សនិងសហគមន៍និងអំពីរបៀបដែលក្រសួងអប់រំបានផ្តល់សេវាកម្ម។

ក្រសួងអប់រំតំបន់ឡុងប៊ីចបានជាប់ឈ្មោះថាជាប្រព័ន្ធសាលាមួយក្នុងចំណោមប្រព័ន្ធសាលារៀនដ៏ល្អនៅក្នុងសហរដ្ឋ ដោយបានឈ្នះពានរង្វាន់ជាច្រើនថាជាគំរូនៃឧត្តមភាពទាំងក្នុងប្រទេសនិងនៅអន្តរជាតិ។ ការសិក្សាស្រាវជ្រាវជាសាកលដោយអង្គការ Battelle for Kids បានរួមបញ្ចូលក្រសួងអប់រំ LBUSD ក្នុងចំណោមប្រព័ន្ធសាលារៀន៥ក្នុងពិភពលោកដែលល្អជាងគេ។ ស្រដៀងគ្នានេះដែរ ក្រសួងអប់រំ LBUSD ត្រូវបានជាប់ថ្នាក់ក្នុងចំណោមប្រព័ន្ធសាលារៀនចំនួន២០ដែលល្អជាងគេក្នុងពិភពលោក ហើយជាប់ថ្នាក់ក្នុងចំណោមប្រព័ន្ធសាលារៀនបីនៅក្នុងសហរដ្ឋ ក្នុងផ្នែកបន្តឲ្យមានការលូតលាស់ជាច្រើន យោងទៅតាមរបាយការណ៍អង្គការ McKinsey & Company ។ ចំពោះផ្នែកការបង្កើនជោគជ័យសិស្សនិងបន្ថយចន្លោះសមិទ្ធិកម្ម ក្រសួងអប់រំបានទទួលរង្វាន់សម្រាប់ការអប់រំ Broad Prize for Urban Education ហើយបានជាប់ឈ្មោះជាអ្នកប្រកួតផ្តាច់ព្រាត់ចំនួន៥លើក។

បង្កើតឡើងនៅឆ្នាំ 1885 ដោយមានសិស្សតែប៉ុន្មាននាក់ហើយជួបគ្នានៅក្រោមរោងខ្ទីគេមួយ បច្ចុប្បន្ននេះ ក្រសួងអប់រំ LBUSD មានសិស្សប្រមាណជា 74,000 នាក់ ពីថ្នាក់ត្រៀមសាលាទៅវិទ្យាល័យ នៅតាមសាលារៀនចំនួន 85 សាលាដែលស្ថិតនៅក្នុងក្រុងឡុងប៊ីច ឡេគវូឌ ស៊ិគណាល់ហៀល និងអាវ៉ាឡូននៃកោះកាតាលីណា។ ដោយមានបុគ្គលិកធ្វើការពេញម៉ោងនិងមិនពេញម៉ោងចំនួនជាង 12,000 នាក់ ក្រសួងអប់រំគឺជានិយោជកធំជាងគេនៅឡុងប៊ីច។ ជាប្រព័ន្ធសាលារៀនធំជាងគេទីបីក្នុងរដ្ឋកាលីហ្វ័រនីញ៉ា LBUSD មានសិស្សចម្រុះសាសន៍ដ៏ច្រើនជាងគេនៅក្នុងសហរដ្ឋ ហើយសិស្សនិយាយភាសាផ្សេងៗពីគ្នាជាច្រើនភាសា។ ប្រមាណជា 54.0% នៃសិស្សគឺសាសន៍និយាយអេស្ប៉ាញ៉ុល 13.5% ជាសិស្សសាសន៍ស្បែកខ្មៅ 13.4% សាសន៍ស្បែកស 7.2% សាសន៍អាស៊ី 3.2% សាសន៍ហ្វីលីពីន 1.5% សាសន៍កោះប៉ាស៊ីហ្វិក និង 0.2% ជាសិស្សជនជាតិដើមនៅអាមេរិក ហើយនៅសល់សិស្សមួយចំនួនទៀតមកពីសាសន៍ផ្សេងៗទៀត។ សិស្សប្រមាណជា 19% គឺជាសិស្សអ្នករៀនភាសាអង់គ្លេស 69% ជាសិស្សចាញ់ប្រៀបគេផ្នែកសង្គមសេដ្ឋកិច្ច និង 9% ជាសិស្សគ្មានទីលំនៅឬរស់នៅជាមួយឪពុកម្តាយចិញ្ចឹម

គន្លឹសដើម្បីទទួលបានជោគជ័យរបស់ក្រសួងអប់រំគឺការធ្វើការជាមួយសហគមន៏ សាលាសាកលវិទ្យាល័យនានា និងឧស្សាហកម្មជាដៃគូរ។ LBUSD, សាកលវិទ្យាល័យ California State University, Long Beach, និងមហាវិទ្យាល័យ Long Beach City College បានធ្វើការជាសហការគ្នាជាមួយស្ថាប័នក្នុងក្រុង ភូមិភាគ និងប្រទេស ដើម្បីបង្កើតការអប់រំគ្មានថ្នេរ តាំងពីថ្នាក់មុនមត្តេយ្យទៅដល់សាកលវិទ្យាល័យ។ សហការណ៏នេះមានរួមទាំងគំរោងកិច្ចសន្យា Long Beach College Promise ដែលផ្តល់ការគាំទ្របន្ថែមទៀតដើម្បីជួយសិស្សឲ្យត្រៀមបំរុងនិងឲ្យមានជោគជ័យនៅសាកលវិទ្យាល័យ។ LBUSD បានបង្កើតដៃគូរក្នុងការអប់រំជាមួយពាណិជ្ជកម្មជាង 1,300 នៅក្នុងតំបន់ដែលទទួលស្គាល់តួរនាទីរបស់ក្រសួងអប់រំក្នុងការបង្កើតកម្លាំងការងារដែលមានការចេះដឹងនិងមានជំនាញខ្ពស់។ មានអ្នកស្ម័គ្រចិត្តជួយសាលាជាង 9,000 នាក់ (VIPS) ជួយគ្រូបង្រៀននិងសិស្សនៅក្នុងថ្នាក់រៀន។ មានប្រធានាធិបតី អគ្គមេធាវី និងលេខាធិការអប់រំបួនជំនាន់ អតីតរដ្ឋលេខាធិការ ឧត្តមសេនីយ៏ Colin Powell ហើយនិងមន្ត្រីជាន់ខ្ពស់ផ្សេងៗបានមកធ្វើទស្សនកិច្ចនៅសាលាឡុងប៊ីច ដើម្បីផ្តល់ការលើកទឹកចិត្តនិងការសិក្សាចម្លងតាមជោគជ័យរបស់ឡុងប៊ីច។ សាលារៀនយើងជាច្រើនបានឈ្នះពានរង្វាន់ជាសាលាល្អប្លែកនៅកាលីហ្វ័រនីញ៉ា និងពានរង្វាន់ផ្សេងៗទៀតក្នុងសហរដ្ឋ ដូចជា National Blue Ribbon, និងពានរង្វាន់ National Green Ribbon ជាដើម។

## ការឆ្លុះបញ្ចាំងចំណុចសំខាន់ៗរបស់ LCAP

ការកត់សម្គាល់រកមើលនិងការសង្ខេបនៃចំណុចសំខាន់ៗរបស់LCAP នៅឆ្នាំនេះ។

LBUSD តាំងចិត្តគាំទ្រដល់ការជោគជ័យផ្ទាល់ខ្លួននិងប្រាជ្ញារបស់សិស្សរាល់រូប រៀងរាល់ថ្ងៃ និងផ្តល់ឲ្យសិស្សទាំងអស់នូវជំរើសជាច្រើនបន្ទាប់ពីរៀនចប់វិទ្យាល័យ។ ជាពិសេសនៅក្នុង LCAP នេះ ក្រសួងអប់រំបានចែករំលែកធនធានសម្រាប់បង្កើតថ្នាក់រៀនអក្សរសិល្ប៍នៅសាលាបឋមសិក្សានិងសាលាថ្នាក់មត្តេយ្យដល់ទី៨ K-8 ( ទំព័ ###); អ្នកផ្តល់ឱវាទ និងការលើកទឹកចិត្តឲ្យយកថ្នាក់កំរិតសាកល Advanced Placement ជាពិសេសទៅដល់សិស្សដែលមកពីគ្រួសារក្រីក្រ (ទំព័រ ###); សេវាកម្មពិនិត្យសុខភាព (ទំព័រ ###); គ្រូប្រចាំបណ្ណាល័យ (ទំព័រ ###); គ្រូផ្នែកចិត្តសាស្ត្រ (ទំព័រ ###); ការជួយរៀបត្រៀមបំរុងសម្រាប់សាកលវិទ្យាល័យនិងអាជីព ដូចជាថ្នាក់កំរិតសាកល "ការសិក្សាពីជនជាតិភាគតិច" និងមាត៏ា Linked Learning (ទំព័រ ###); សេវាកម្មសម្រាប់សិស្សរស់នៅជាកូនចិញ្ចឹម (ទំព័រ ###); និងកម្មវិធីដែលយកចិត្តទុកដាក់លើការបង្ការការពារ និងការឆាប់ធ្វើអន្តរាគម និងកម្មវិធីសម្រាប់ជាអ្នកដឹកនាំសម្រាប់សិស្សដែលមានកោសល្យដែលមកពីក្រុមគ្រួសារក្រីក្រចាញ់ប្រៀបគេ (ទំព័រ ###); រួមទាំងកម្មវិធីគាំទ្រផ្សេងៗទៀតនៅតាមសាលារៀន។ ថវិការនិងការពន្យល់ក្បោះក្បាយមានផ្តល់ឲ្យនៅក្នុងផ្នែកវគ្គ គោលដៅ សកម្មភាព និងសេវាកម្ម។

ចំណាយទាំងនេះគឺតម្រង់សម្រាប់ធ្វើឲ្យប្រសើរឡើងដល់ការសិក្សារបស់សិស្សមកពីគ្រួសារក្រីក្រ សិស្សអ្នករៀនភាសាអង់គ្លេស សិស្សដែលទើបកត់សម្គាល់ចេះភាសាអង់គ្លេសស្ទាត់ និងសិស្សជាកូនចិញ្ចឹម ដោយបង្កើនសេវាកម្មឲ្យទូលំទូលាយដែលសិស្សត្រូវការដើម្បីឲ្យបានទទួលជោគជ័យក្នុងការសិក្សា បិទចន្លោះសមិទ្ធិកម្ម ហើយបង្ហាញភាពរួចរាល់សម្រាប់សាកលវិទ្យាល័យនិងអាជីព។ សេវាកម្មទាំងនេះគឺសម្រាប់ផ្តល់ឲ្យនៅក្នុងក្រសួងអប់រំទាំងមូលនិងនៅសាលារៀន។ ដូចដែលបានទទួលស្គាល់ដោយអង្គការ Broad Prize និងបានបញ្ជាក់អះអាងដោយការសិក្សាស្រាវជ្រាវអំពីការសិក្សា ការផ្តល់សេវាកម្មជាលក្ខណៈក្នុងក្រសួងអប់រំទាំងមូល គឺជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធិភាពសម្រាប់ក្រសួងអប់រំដូចជា LBUSD ជាដើម ដែលសិស្សនិងគ្រួសារមានអត្រាខ្ពស់ក្នុងការធ្វើចល័តនិងជំរើសសាលារៀន។ វាបញ្ជាក់នូវសមភាពទូទាំងសហគមនដ៏ចម្រុះពូជសាសន៏ដែលមានរួមនូវទីក្រុង Long Beach, Lakewood, Signal Hill, និង Avalon លើកោះ Catalina ។ ថែមពីនោះទៀតវាបង្កើតប្រសិទ្ធិភាពនិងជញ្ជីងសេដ្ឋកិច្ចដែលធ្វើឲ្យការចំណាយមានប្រសិទ្ធិភាពជាអតិបរិមាណ។

ខណៈដែលចំណាយក្នុងក្រសួងអប់រំទាំងមូលមានជាទូទៅ សេវាកម្មគឺយកចិត្តទុកដាក់តម្រង់ទៅលើសេចក្តីត្រូវការរបស់សិស្ស។ ចំណែកសិស្សមួយចំនួនដែលមិនជួបប្រទះនឹងការលំបាកក្នុងការសិក្សា គឺមិនបានទទួលជំនួយដូចសិស្សទូទៅនោះទេ។ អ្វីត្រូវគិតគូរមុនគេគឺសិស្សដែលត្រូវការជំនួយខ្លាំង។ ឧទាហរណ៏ កម្មវិធី Male and Female Leadership Academies ទទួលស្វាគមន៏សិស្សទាំងអស់ ប៉ុន្តែសិស្សចូលរួមគឺច្រើនតែសិស្សដែលត្រូវការជំនួយច្រើនជាងគេ។

នៅក្នុងប្រព័ន្ធសាលារៀនធំៗ សេចក្តីត្រូវការរបស់សិស្ស ជួនកាលសង្កត់ធ្ងន់ទៅលើចំណុចពិសេសៗ។ នៅក្នុងករណីដូចនេះ យើងផ្តល់ជំនួយទៅតាមការចាំបាច់របស់សាលាលរៀននីមួយៗ ដែលអនុញ្ញាតឲ្យយើងផ្តល់សេវាដល់ចំណុចដែលចាំបាច់ ស្របពេលដែលយើងរក្សាជីញ្ជីងសេដ្ឋកិច្ចនិងភាពបត់បែនរបស់សាលារៀន។ សម្រាប់ផែនការនេះ ក្នុងសហការជាមួយអង្គការផ្សេងៗក្នុងសហគមន៏ ក្រសួងអប់រំ LBUSD បានរកឃើញសាលាចំនួន៣០ដែលជាសាលាត្រូវការជំនួយខ្ពស់ ដែលមានសិស្សមកពីគ្រួសារក្រីក្រច្រើន ហើយសាលាទាំងនោះនឹងបានទទួលជំនួយច្រើនជាងគេ ជាពិសេសសម្រាប់សេវាកម្មដែលមានរួមទាំង:

សេវាកម្មផ្លូវចិត្ត / សេវាកម្មគាំទ្រសង្គមកិច្ច

- ជ្រើសរើសសាលារៀនដែលត្រូវការជំនួយខ្ពស់ នឹងមានសមាមាត្រ ២៥០:១ នៃសិស្សទៅនឹងអ្នកផ្តល់ឱវាទ។
- សាលាដ៏ទៃទៀតនឹងបន្តផ្តល់មណ្ឌលសេវាកម្មគាំទ្រសុខភាពផ្លូវចិត្តដែលសិស្សប្រើប្រាសបាន។

ការបង្ហាត់បង្រៀនបន្ថែម

- ដោយមានការណែនាំច្បាស់លាស់ពីក្រសួងអប់រំ សាលាដែលត្រូវការជំនួយខ្លាំងទាំង៣០នឹងបង្កើតឬបន្តផ្តល់ការបង្ហាត់បង្រៀនបន្ថែមនៅសាលាដែលសំដៅទៅលើមុខវិជ្ជាភាសាសិល្ប៏អង់គ្លេសនិងគណិតវិទ្យា។
- សិស្សដែលត្រូវការជំនួយខ្លាំងជាងគេនឹងមានអាទិភាពខ្ពស់ជាងគេសម្រាប់បានទទួលសេវាកម្មនេះ

ដោយជ្រើសរើសសាលាដែលត្រូវការជំនួយខ្លាំងចំនួន៣០ ក្រសួងអប់រំ LBUSD ជាស្វ័យប្រវត្ត បង្កើនគុណភាពសេវាកម្មសម្រាប់សិស្សណាដែលត្រូវការជំនួយជាងគេ។ ដូចគ្នាទៅនឹងការផ្តល់សេវាទូទាំងក្រសួងអប់រំទាំងមូលដែរ ការផ្តល់ធនធានផ្តល់សេវាកម្មនៅតាមសាលារៀនគឺសំដៅទៅលើសិស្សដែលត្រូវការជំនួយច្រើនជាងគេ ពីព្រោះពួកគេត្រូវការជំនួនច្រើនជាពិសេសសេវាកម្មដែលបានបង្កើនគុណភាព។

## ការពិនិត្យមើលឡើងវិញនូវលទ្ធផល

យោងតាមការពិនិត្យមើលលទ្ធផលតាមសញ្ញាបង្ហាញរបស់រដ្ឋនិងក្រសួងអប់រំ ដែលរាប់បញ្ចូលផងដែរនូវរង្វាស់ប៉ាន់ស្មាន LCAP អំពីផ្នែកលូតលាស់មកកាន់គោលដៅ យោបល់ពីអ្នកមានភាគហ៊ុន ដែលមានមុខងារក្នុងកម្មវិធីសិក្សានិងកម្មវិធីផ្សេងៗ តើភាពលូតលាស់អ្វីដែលក្រសួងអប់រំមានមោទនភាពជាងគេ និងតើក្រសួងអប់រំមានផែនការរក្សា និងបង្កើនភាពជោគជ័យតាមវិធីណា? នេះអាចរាប់ចូលទាំងឧទាហរណ៏ដែលបានប្រើពីពេលមុនមកសម្រាប់បង្កើនជំនួយដល់សិស្សមកពីគ្រួសារក្រីក្រ សិស្សរៀនភាសាអង់គ្លេស និងសិស្សជាកូនចិញ្ចឹម ដែលបានទទួលលទ្ធផលលូតលាស់។

### ការលូតលាស់ដ៏ធំធេង

ក្រសួងអប់រំ LBUSD បានមានការលូតលាស់ជាច្រើនលើផ្នែករៀបបំរុងសិស្សទាំងអស់ ជាពិសេសសិស្សក្នុងកម្មវិធីពិសេស សម្រាប់ការសិក្សានៅសាកលវិទ្យាល័យនិងអាជីព។ អត្រាសិស្សដែលរៀនចប់ពីវិទ្យាល័យបន្តកើនឡើងហើយច្រើនជាងក្រសួងអប់រំនានានៅក្នុងរដ្ឋ ជាពិសេសក្នុងចំណោមក្រុមសិស្សនៃជនជាតិភាគតិច។ ខណៈដែលក្រសួងអប់រំបានទទួលលទ្ធផលល្អលើការលូតលាស់ជាទូទៅនៅក្នុងតារាងពិន្ទុរដ្ឋកាលីហ្វ័រនីញ៉ា សិស្សស្បែកខ្មៅ ហ៊ិសស្ប៉ានិក អាស៊ី កោះប៉ាស៊ីហ្វិក សាសន៏ស និងសិស្សដែលមកពីគ្រួសារក្រីក្រក៏មានការលូតលាស់ល្អដែរ។ ខណៈដែលសិស្សនៅរៀនភាសាអង់គ្លេសបានទទួលលទ្ធផលកំរិតពណ៌លឿងពួកគេក៏មានការលូតលាស់ជាច្រើនដែរ។

ក្រសួងអប់រំ LBUSD បានទទួលការលូតលាស់នៅពេលដែលសិស្សបានយកថ្នាក់ពិបាកៗកាន់តែច្រើន។ ក្នុងឆ្នាំសិក្សាបច្ចុប្បន្ននេះ 47% នៃសិស្សថ្នាក់ទី 11th និងទី 12th បានចុះឈ្មោះរៀនថ្នាក់កំរិតសាកលវិទ្យាល័យយ៉ាងតិចក៏មួយថ្នាក់ដែរ ដែលស្មើគ្នានឹងចំនួនកាលពីឆ្នាំមុន ហើយដែលមានការកើនឡើងចំនួន៥ភាគរយពីឆ្នាំ២០១៥-២០១៦។ សិស្សស្បែកខ្មៅ ហ៊ិសស្ប៉ានិក អ្នករៀនភាសាអង់គ្លេស សិស្សដែលទើបបានចាត់ទុកថាចេះភាសាអង់គ្លេសគ្រប់គ្រាន់ (RFEPs) និងក្រុមសិស្សជនជាតិភាគតិច បានកើនចំនួនឡើងក្នុងការចូលរួម។ ស្របពេលជាមួយគ្នានេះដែរ សមាមាត្រនៃសិស្សដែលរៀនចប់ពីវិទ្យាល័យនៅ LBUSD ដែលរៀនបានស្របតាមតម្រូវការនៃថ្នាក់ជំពូក a-g ក៏បានកើនឡើងពី 45% ទៅ 49% ហើយសិស្សជនជាតិភាគតិចបានបិទចន្លោះសមិទ្ធិកម្មកាន់តែជិត។

កិច្ចការរៀបត្រៀមបំរុងទាំងនេះបានផ្តល់ជាលទ្ធផលឲ្យសិស្សមានឱកាសជាច្រើនបន្ទាប់ពីរៀនចប់សាលាវិទ្យាល័យ។ យោងទៅតាមទិន្នន័យដែលមានកន្លងមកថ្មីៗនេះពីអង្គការ National Student Clearinghouse, 72% នៃសិស្សដែលរៀនចប់ពីវិទ្យាល័យនៅ LBUSD បានចុះឈ្មោះរៀននៅសាលាមហាវិទ្យាល័យ២ឆ្នាំឬ៤ឆ្នាំក្នុងអំឡុងពេល១ឆ្នាំបន្ទាប់ពីបានទទួលសញ្ញាប័ត្រវិទ្យាល័យ។ អត្រានៃការចូលរៀននៅសាកលវិទ្យាល័យនេះគឺប្រហាក់ប្រហែលនឹងមធ្យមភាពក្នុងប្រទេសដែរហើយបន្តមានភាពឋិតថេរបីឆ្នាំកន្លងមកនេះ។ ចំនួនប្រាក់អាហារូបករណ៏និងជំនួយបង់ថ្លៃសាលាសាកលវិទ្យាល័យមានចំនួនជាង $90 លាន ដែលមានចំនួនច្រើនជាង៥ដងក្នុងរយៈពល១០ឆ្នាំកន្លងមក។

រយៈពេល១០ឆ្នាំនេះគឺត្រូវគ្នាទៅនឹងរយៈពេលនៃគំរោងកិច្ចសន្យាឡុងប៊ីចផងដែរ ដែលបានផ្តល់ប្រយោជន៏ជាច្រើនដល់សិស្សនៅទីនេះ។ ក្រសួងអប់រំ LBUSD បានឃើញការកើនឡើងទាំងផ្នែកមានសិទ្ធទៅរៀននិងផ្នែកបានចុះឈ្មោះទៅរៀននៅសាកលវិទ្យាល័យក្នុងរដ្ឋកាលីហ្វ័រនីញ៉ា CSULB ចំនួន 71% ។ក្នុងចំណោមសិស្សដែលមិនបានកើតនៅអាមេរិក ហើយដែលជាសិស្សមកពីគ្រួសារក្រីក្រ ការកើនឡើងក្នុងការចូលរៀនមានចំនួនប្រមាណ 60% ។ ភាពរួចរាល់សម្រាប់សាកលវិទ្យាល័យក៏បានកើនឡើងដែរ ខណៈដែលអត្រានៃការជួយប៉ះប៉ូវបានចុះថយពី 57% ទៅ 35% ហើយមានសិស្សកាន់តែច្រើនបានរៀនវិស័យវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វៈកម្ម និងគណិតសាស្ត្រ (STEM) ដែលកើនឡើង 62% នៅសាលា CSULB និង 97% នៅសាលា LBCC ។ លូតលាស់

ការបន្ថែមនូវឱកាសបន្ទាប់ពីរៀនចប់សាលាលវិទ្យាល័យបានកើតឡើងស្របគ្នានឹងការលូតលាស់ពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី១២ ក្នុងមុខវិជ្ជាសំខាន់ៗ ជាពិសេសភាសាសិល្ប៏និងគណិតវិទ្យា។ ដូចបានបង្ហាញនៅក្នុងតារាង

លទ្ធផលរដ្ឋ ខណៈដែល LBUSD បានទទួលលទ្ធផលពិន្ទុពណ៌លឿងផ្នែកភាសាសិល្បិ៍ គ្រប់ក្រុមសិស្សជនជាតិភាគតិចទាំងអស់មានការលូតលាស់ឬលូតលាស់ជាច្រើន រួមទាំងសិស្សមកពីគ្រួសារក្រីក្រ អ្នករៀនភាសាអង់គ្លេស ស្បែកខ្មៅ ហ៊ិសស្ប៉ានិក និងសិស្សអសមត្ថភាព ក៏មានការលូតលាស់ឡើងដែរ។ ស្រដៀងគ្នានេះ លើកលែងតែក្រុមសិស្សជនជាតិភាគតិចពីរក្រុម គឺមានការលូតលាស់លើគណិតវិទ្យា។ សង្ខេបទៅក្រសួងអប់រំ LBUSD ធ្វើបានសម្រេចតាមគោលដៅប្រចាំឆ្នាំដែលបានរំពឹងទុកក្នុងមុខវិជ្ជាទាំងពីរនៅឆ្នាំនេះ។

បន្ថែមពីសមិទ្ធិកម្មនៃការសិក្សា ការលូតលាស់ដូចគ្នាក៏មានលើផ្នែកផ្លូវចិត្តសង្គមនិងបរិយាកាសសាលារៀនផងដែរ។ ការបញ្ឈប់សិស្សពីរៀននៅ LBUSD បន្តមានការចុះថយ ហើយបានទទួល ពិន្ទុពណ៌បៃតងជាសារុប។ ការកើនឡើងនេះគឺមានចំពោះសិស្សមកពីគ្រួសារក្រីក្រ អ្នករៀនភាសាអង់គ្លេស ស្បែកខ្មៅ ហ៊ិសស្ប៉ានិក សិស្សជាកូនចិញ្ចឹម សិស្សគ្មានទីលំនៅ និងសិស្សអសមត្ថភាព។ វត្តមានសាលាអវត្តមានរ៉ាំរ៉ៃ ការបោះបង់ចោលការសិក្សា ទាំងអស់បានមានការផ្លាស់ប្តូរជាវិជ្ជមាន យោងតាមការសង្កេតមើលដោយលទ្ធផលនៃការស្ទង់មតិ។ យោងតាមចម្លើយចំនួន 46,000 សិស្សបីភាគបួនបានឲ្យដឹងថាបរិយាកាសល្អនៅសាលាគាំទ្រដល់ការសិក្សា។ ចំណែកមាតាបិតា ប្រហែលជា 25,000 ចម្លើយ និងបុគ្គលិកសាលាប្រមាណជា 4,800 ចម្លើយ 90% បានឆ្លើយដោយឲ្យពិន្ទុល្អដល់ក្រសួងអប់រំ។

ការលូតលាស់ទាំងប៉ុន្មានដែលបានរាបរាប់មកនេះ បានកើតមានឡើងដោយសារតែការតាំងចិត្តរបស់ក្រសួងអប់រំ LBUSD ក្នុងការរក្សានិងពង្រឹងប្រព័ន្ធមូលដ្ឋានគ្រឹះនៃការអប់រំ។ ក្នុងចំណោមក្រសួងអប់រំធំៗនៅរដ្ឋកាលីហ្វ័រនីញ៉ា Long Beach មានអត្រាអនុវត្តស្របតាមច្បាប់រដ្ឋខ្ពស់ជាងគេ ទាំងផ្នែកមានគ្រូបង្រៀនដែលមានសារតាំងពេញលេញនិងការចាត់តាំងឲ្យបង្រៀនបានត្រឹមត្រូវទៅតាមមុខជំនាញរបស់គ្រូ។ បីឆ្នាំជាប់គ្នា 100% នៃសាលារៀនបានទទួលលិទ្ធផលខ្ពស់ ផ្នែកមានភាពស្អាតបាតនិងមានសុវត្ថិភាព យោងទៅតាមការពិនិត្យមើលអគារសាលារៀន។ ចំណែកផ្នែកសម្ភារៈសិក្សានិងការដាក់ប្រតិបត្តិនូវមុខវិជ្ជាស្នូលសាមញ្ញ LBUSD ក៏បានទទួលលទ្ធផលល្អដូចគ្នា។ ក្នុងស្ថានភាពដ៏ពិបាកដែលប្រឈមមុខនឹងសហគមន៍ដែលមានពូជសាសន៍ដ៏ចម្រុះ ជោគជ័យទាំងនេះគួរតែត្រូវបានកត់សម្គាល់ ព្រោះវាពិបាកនឹងទទួលបាននៅក្នុងកាលៈទេសៈនេះ។ ប្រាកដណាស់ វាត្រូវការផែនការនិងវិនិយោគទូទាំងក្រសួងអប់រំ ដែលជាកិច្ចខំប្រឹងប្រែងសកម្មមួយដើម្បីបញ្ជាក់ថា LBUSD អាចទាក់ទាញនិងរក្សាទុកគ្រូបង្រៀន ព្រមទាំងការបណ្តុះបរិស្ថានសិក្សាមួយដែលសិស្ស ជាពិសេសសិស្សដែលត្រូវការជំនួយពិសេស អាចមានការលូតលាស់។ យុទ្ធសាស្រ្តដែលសង្កត់យកចិត្តទុកដាក់លើប្រព័ន្ធមូលដ្ឋានគ្រឹះរបៀបនេះ អនុញ្ញាតឲ្យក្រសួងអប់រំបិទចន្លោះសមិទ្ធិកម្មនៅក្នុងពេលខ្លីនិងទៅថ្ងៃមុខជាយូរអង្វែង។

យោងតាមរង្វាស់ប៉ាន់ស្មាន LCFF សូមរកមើលនៅតាមសញ្ញាបង្ហាញរបស់រដ្ឋ ឬក្រសួងអប់រំ ដែលលើកបង្ហាញលទ្ធផលពណ៌ “Red” ឬពណ៌ “Orange” ឬលទ្ធផលដែលបង្ហាញ “Not Met” ឬ “Not Met for Two or More Years” ។ បន្ថែមទៀតគឺសូមរកមើលចំណុចណាដែលក្រសួងអប់រំបានរកឃើញថាត្រូវការភាពលូតលាស់ច្រើន ដោយយោងតាមសញ្ញាបង្ហាញពីក្រសួងអប់រំនៅតំបន់ផ្សេងៗ។ តើក្រសួងអប់រំមានផែនការដោះស្រាយតាមចំណែកទាំងអស់នេះតាមវិធីណាដើម្បីជួយសិស្សត្រូវការជំនួយច្រើនជាងគេឲ្យមានការលូតលាស់?

## សេចក្តីចាំបាច់ខ្លាំង

ក្រសួងអប់រំ LBUSD បានមានការលូតលាស់យ៉ាងច្រើនទៅលើច្រើនផ្នែក ដោយពុំមានលទ្ធផលមួយណាស្ថិតនៅក្រោមកំរិតលទ្ធផលទាបជាងគេពីរ សម្រាប់សិស្សទាំងអស់ ដែលជាការលូតលាស់ជាងពីឆ្នាំមុនដែលមានលទ្ធផលមួយកំរិត “Orange”។ LBUSD ក៏ធ្វើបានដូចតាមសញ្ញាបង្ហាញទាំងអស់របស់ខ្លួនដែរ។

នៅស្របពេលជាមួយគ្នា ចន្លោះសមិទ្ធិកម្មនៅតែបន្តមាន។ LBUSD បានធ្វើអាទិភាពក្នុងការវិភាគទិន្នន័យថ្មីៗជាងគេដោយផ្ចិតផ្ចង់ហើយបង្កើនការខ្នះខ្នែងដើម្បីធ្វើឲ្យមានសមិទ្ធិកម្មលឿន ជាពិសេសក្នុងចំណោមសិស្សស្បែកខ្មៅ ហ៊ិសស្ប៉ានិក អ្នករៀនភាសាអង់គ្លេស សិស្សទើបបានចាត់ទុកថាចេះភាសាអង់គ្លេសគ្រប់គ្រាន់ សិស្សអសមត្ថភាព សិស្សគ្មានទីលំនៅនិងសិស្សជាកូនចិញ្ចឹម។ ចន្លោះទាំងនេះមានពិភាក្សានៅខាងក្រោម។

ដោយសំអាងទៅលើរង្វាស់ប៉ាន់ស្មាន LCFF សូមរកមើលតាមសញ្ញាបង្ហាញរបស់រដ្ឋ ឬក្រសួងអប់រំ ដែលបញ្ជាក់អំពីសិស្សមកពីក្រុមណាមួយ ដែលបានទទួលលទ្ធផលជាកំរិតទាបពីរកំរិតឬច្រើនជាង នៃលទ្ធផលសិស្សទាំងអស់។ តើក្រសួងអប់រំមានផែនការដោះស្រាយតាមវិធីណា?

**ចន្លោះលទ្ធផល**

ទោះបីជាក្រសួងអប់រំ LBUSD បានមានការល្អតលាស់លើច្រើនផ្នែក ហើយបានបិទចន្លោះសមិទ្ធិកម្មក៏ ដោយ នៅមានផ្នែកខ្លះទៀតដែលក្រុមសិស្សជនជាតិភាគតិចមានលទ្ធផលទាបជាងគេយ៉ាងតិច២កំរិតទាបជាងលទ្ធផលរបស់សិស្សទាំងអស់។

- អត្រានៃការបញ្ឈប់ពីរៀនលើសិស្សស្បែកខ្មៅ សិស្សជនជាតិដើមអាមេរិកាំង និងសិស្សជាកូនចិញ្ចឹម ខណៈដែលមានការចុះអន់ថយ 1.1%, 0.2%, និង 0.3%, ពួកគេត្រូវបានផ្តល់លទ្ធផលកំរិតពណ៌ "Orange" ទោះបីជាលទ្ធផលជាទូទៅរបស់ ក្រសួងអប់រំមានពណ៌ "Green" ហើយ

- អត្រានៃការរៀនចប់ពីវិទ្យាល័យរបស់សិស្សជាកូនចិញ្ចឹមនិងសិស្សអសមត្ថភាព ខណៈដែលលទ្ធផលរបស់ក្រុមនេះបានកើនឡើង ពួកគេបានទទួលលទ្ធផលពណ៌ "Red" ដែលជា កំរិត"យ៉ាងទាប" ប្រៀបធៀមទៅនឹងលទ្ធផលល្អពណ៌ "Green" របស់សិស្សទាំងអស់។

លទ្ធផលទាំងនេះបានមកពីតារាងលទ្ធផលសាលារដ្ឋ California School Dashboard ដែលបានចុះផ្សាយពីចុងឆ្នាំ 2017 ។ របាយការណ៍បង្ហាញឲ្យឃើញថា LBUSD បានមានការល្អតលាស់លើចន្លោះសមិទ្ធិកម្មពីរផ្នែក កាលពីឆ្នាំមុន រួមទាំងអត្រានៃការបញ្ឈប់សិស្សពីរៀនសម្រាប់សិស្សអ្នករៀនភាសាអង់គ្លេសនិងសិស្សអសមត្ថភាពដែល បច្ចុប្បន្ននេះមានលទ្ធផលកំរិតពណ៌ "Green" និង "Yellow" ។ LBUSD គ្រោងនឹងបន្តធ្វើកិច្ចការនេះតាមវិធីខាងក្រោមនេះ:

- បន្ថែមសេវាកម្មដែលបានផ្តល់ឲ្យដោយអ្នកផ្តល់ឱវាទ ជាពិសេសនៅសាលាដែលត្រូវការខ្លាំង។ បុគ្គលិកបន្ថែមនឹងជួយពង្រីកចំនួនថ្នាក់អប់រំជាក្រុមតូចៗដែលទាក់ទងនឹងបញ្ហាដែលរារាំងដល់ការសិក្សារបស់សិស្ស ឥរិយាបថ ឬការល្អតលាស់ផ្នែកផ្លូវចិត្តនិងសង្គម។

- បង្កើតមណ្ឌលមួយចំនួនដែលផ្តល់សេវាដោះស្រាយបញ្ហាការសិក្សា សុខភាពផ្លូវចិត្តនិងសេចក្តីចាំបាច់ផ្សេងៗរបស់សិស្ស ជាពិសេសសិស្សក្នុងលក្ខណៈពិសេស។ មណ្ឌលទាំងនេះនឹងជួយបង្កើនសេវាកម្មហើយចែកចាយព័ត៌មានពីសុខភាពដល់គ្រួសារសិស្ស។ យោងតាមយោបលពីអ្នកជាក់ភាគហ៊ុន សេវាកម្មហ្វឹកហ្វឺនមាតាបិតាក៏នឹងផ្តល់ឲ្យដែរ។

- បន្ថែមម៉ោងបង្ហាត់បង្រៀនបន្ថែមនៅសាលាក្នុងមុខវិជ្ជាភាសាសិល្បិ៍អង់គ្លេសនិងគណិតវិទ្យា ជាពិសេសនៅសាលាដែលមានការចាំបាច់ខ្លាំង។ សិស្សដែលត្រូវការជំនួយខ្លាំងនឹងទទួលការគាំទ្រយោងទៅតាមសេចក្តីចាំបាច់ផ្ទាល់ខ្លួន។

- ពង្រីកកម្មវិធី CSULB-LBUSD Math Collaborative, ដែលជាកម្មវិធីមួយរវាងក្រសួងអប់រំនិងសាកលវិទ្យាល័យ California State University, Long Beach ដែលផ្តល់ការគាំទ្របន្ថែមដើម្បីជួយសិស្សក្នុងលក្ខណៈពិសេសឲ្យរៀនចប់ពីវិទ្យាល័យហើយរៀបបំរុងសម្រាប់សាកលវិទ្យាល័យ។ ការសាកល្បងនៃកម្មវិធីបានបង្ហាញថាមានប្រយោជន៍ដល់សិស្សស្បែកខ្មៅនៅវិទ្យាល័យ Jordan ។ សេវាកម្មនេះមានរួមទាំងការបង្ហាត់បន្ថែមថ្នាក់គណិតវិទ្យាក្នុងរយៈពេលពីរសប្តាហ៍ក្នុងរដូវក្តៅនៅសាកលវិទ្យាល័យ CSULB។

- បង្កើតការបន្ថយចំនួនសិស្សក្នុងថ្នាក់នៅតាមសាលាវិទ្យាល័យ៦ ដែលមានអត្រាបញ្ឈប់សិស្សពីរៀនខ្ពស់ជាពិសេសសិស្សក្នុងលក្ខណៈពិសេស ហើយសាលាដែលមានប្រវត្តខ្សោយជាងសាលាដ៏ទៃនៅក្នុងក្រសួងអប់រំ។ ផែនការនេះនឹងមានដំណើរការស្របគ្នាជាមួយកម្មវិធី បន្ថែមថ្នាក់អក្សរសិល្បិ៍នៅសាលាបឋមសិក្សានិងសាលា K-8 ដើម្បីបញ្ជាក់ថាសិស្សបាន ទទួលសេវាកម្មបន្ថែម។ .

- បង្កើនសេវាកម្មអប់រំនិងសេវាកម្មផ្សេងៗទៀតដល់សិស្សសាលាមធ្យមសិក្សា ជាពិសេសនៅសាលាដែលមានការចាំបាច់ខ្លាំង ដើម្បីឲ្យពួកគេត្រៀមខ្លួនបានល្អសម្រាប់រៀនកម្មវិធីពិសេសនៅសាលាវិទ្យាល័យ។ សេវាកម្មទាំងនេះនឹងមានជួលបុគ្គលិកបន្ថែមដែលអាចផ្តល់ឱវាទនិងការណែនាំលើកទឹកចិត្ត ព្រមទាំងកម្មវិធីក្នុងវគ្គរដូវក្តៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វៈកម្មនិងគណិតសាស្ត្រ។

បន្ថែមពីលើកម្មវិធីទាំងនេះ LBUSD នឹងបន្តធ្វើឲ្យប្រសើរឡើងដល់ការហ្វឹកហ្វឺនបុគ្គលិកសម្រាប់គ្រូបង្រៀននិងបុគ្គលិកដ៏ទៃទៀតដើម្បីឲ្យពួកគេអាចផ្តល់សេវាកម្មដែលមានប្រសិទ្ធិភាពដល់សេចក្តីចាំបាច់របស់សិស្សក្នុងលក្ខណៈពិសេស។ ឧទាហរណ៍ៈ ការហ្វឹកហ្វឺនមួយបានគាំទ្រដល់អ្នកផ្តល់ឱវាទនិងអភិបាលសាលា K-12 គឺការហ្វឹកហ្វឺនអំពីសិស្សគ្មានទីលំនៅនិងសិស្សដែលគេយកទៅចិញ្ចឹម ដែលផ្តល់ការពន្យល់អំពីបទបញ្ញា ច្បាប់វិន័យសំខាន់ៗ និងប្រភេទនៃសេវាកម្មផ្លូវចិត្តដែលមានសម្រាប់សិស្សទាំងនេះ។ ប្រធានបទសំខាន់ៗមានរួមទាំង McKinney Vento, សំណួរពីទីលំនៅរបស់សិស្ស ការពន្យល់អត្ថន័យសិស្សដែលគេយកទៅចិញ្ចឹមក្រោមផែនការ LCFF និង ការបញ្ជូលទៅទល់នឹងករណីដែលកំពុងប្រតិបត្តិ “Referral vs. Open Case,” រួមទាំងប្រធានបទផ្សេងៗទៀត។ អ្នកចូលរួមក្នុងការហ្វឹកហ្វឺនក៏មានឱកាសសហការជាមួយនាយកដ្ឋានសិស្សគេយកទៅចិញ្ចឹមផងដែរ។ ស្របគ្នានឹងការបង្ហាញនេះ ថ្នាក់ហ្វឹកហ្វឺនបុគ្គលិកផ្សេងៗទៀតសំដៅទៅផ្នែកចន្លោះសមិទ្ធិកម្មដែលបានរកឃើញខាងលើ។

ថែមពីនោះទៀត LBUSD នឹងបន្តពិនិត្យមើលការអនុវត្តដែលមានប្រសិទ្ធិភាពនៅតាមសាលារៀននីមួយៗហើយពិចារណាយកវាធ្វើជារង្វាស់។ ឧទាហរណ៍ៈ សាលា Cabrillo មានបើកថ្នាក់បង្រៀននៅថ្ងៃសៅរ៍ដែលតម្រង់សម្រាប់គាំទ្រសិស្សផ្នែករៀនឲ្យចប់ពីវិទ្យាល័យនិងឱកាសផ្សេងៗបន្ទាប់ពីរៀនចប់វិទ្យាល័យ។ សមាជិករបស់គណកម្មាធិការអ្នករៀនភាសាអង់គ្លេសរបស់ក្រសួងអប់រំបានចោតសំណួរដល់លោកអគ្គនាយកសាលាអំពីរបៀបដែលកម្មវិធីដូចនេះអាចបើកឲ្យនៅសាលាផ្សេងៗទៀត។ វានឹងមានពង្រីកនៅសាលាផ្សេងៗទៀត។

វិធានការផ្សេងៗទៀតស្រដៀងគ្នានេះដែរនឹងអនុវត្តដើម្បីបង្កើនអត្រារៀនចប់ពីវិទ្យាល័យសម្រាប់សិស្សអសមត្ថភាព។ ការឆ្លុះបញ្ចាំងឲ្យច្បាស់មានរួមទាំងៈ

- ដែកពិនិត្យមើលស្ថានភាពរៀនចប់ពីវិទ្យាល័យសម្រាប់សិស្សនៅពេលប្រជុំកម្មវិធីសិក្សាផ្ទាល់ខ្លួន (IEP) ដើម្បីជួយការរៀបចំគ្រោងការសិក្សា។
- បង្កើនការហ្វឹកហ្វឺនបុគ្គលិកផ្នែកផែនការផ្ទេរសិស្សនិងរៀបបំរុងសម្រាប់ក្រុម IEP នៅសាលាវិទ្យាល័យ។
- ផ្តល់ការហ្វឹកហ្វឺនបុគ្គលិកដល់មេនាយកដ្ឋានមុខវិជ្ជានៅវិទ្យាល័យដើម្បីបញ្ជាក់ការរៀនចប់ពីវិទ្យាល័យត្រូវបានទទួលការយកចិត្តទុកដាក់។
- ដាក់អនុវត្តនូវកម្មវិធីសិក្សាដែលបង្កើនសក្តានុពលរបស់សិស្សដែលមានរួមទាំងអន្តរាគមនៅពេលចាំបាច់ដើម្បីបង្កើនល្បឿនឲ្យឆាប់រៀនចប់ពីវិទ្យាល័យ។
- បង្កើនលទ្ធភាពចូលរៀនក្នុងកម្មវិធីពិសេសៗដែលគាំទ្រដល់ការងារបន្ទាប់ពីរៀនចប់វិទ្យាល័យហើយបង្កើតបណ្តាញទំនាក់ទំនងជាមួយកម្មសិក្សា
- សហការជាមួយមណ្ឌល Harbor Regional Center សម្រាប់រៀបគ្រោងពេលរៀនចប់ពីវិទ្យាល័យ

ជាចុងក្រោយ LBUSD នឹងអនុវត្តវិធានការទាំងនេះនិងផ្សេងៗទៀតដើម្បីបង្កើនសេវាកម្មដល់សិស្សដែលគេយកទៅចិញ្ចឹមៈ

- សហការជាមួយមហាវិទ្យាល័យដើម្បីរកសិស្សកំពុងរៀនវិស័យអនុបណ្ឌិតផ្នែកសង្គមកិច្ចសម្រាប់ធ្វើការជាមួយសិស្សជាកូនចិញ្ចឹម (FYU) ដើម្បីបង្កើនទំនាក់ទំនងនិងចាត់ចែងករណីសំណុំរឿងសិស្ស។
- ផ្តល់ការហ្វឹកហ្វឺនបុគ្គលិកស្តីពីបញ្ហាផ្លូវចិត្តដល់អ្នកផ្តល់ឱវាទសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យនៅ LBUSD ដើម្បីឲ្យពួកគាត់យល់ដឹងអំពីភាពលំបាកដែលសិស្សគេយកទៅចិញ្ចឹមកំពុងប្រឈមមុខ។
- ផ្តល់ការហ្វឹកហ្វឺនបុគ្គលិកដល់បុគ្គលិកជំនួយនៅសាលារៀនអំពីសាលារៀនដើមរបស់សិស្ស អាណាព្យាបាល និងនីតិវិធីចុះឈ្មោះដើម្បីឲ្យសិស្សដែលជាកូនចិញ្ចឹមបានចុះឈ្មោះទាន់ពេលវេលា។
- បង្កើនការហ្វឹកហ្វឺនបុគ្គលិកដល់ពេទ្យប្រចាំសាលាស្តីពីបញ្ហាទាក់ទងនឹងសុខភាពនិងច្បាប់ស្តីពីការចែកចាយព័ត៌មានសិស្ស ហើយនិងដល់គ្រូបង្រៀនថ្មីៗអំពីសេវាកម្មសម្រាប់សិស្សជាកូនចិញ្ចឹមនិងច្បាប់ទាក់ទិន។
- ផ្តល់ព័ត៌មានស្តីអំពីរបៀបរាយការណ៍ថ្មីតាមរយៈអនឡាញស្តីពីការធ្វើបាបក្មេងដល់អភិបាលសាលា LBUSD
- សហការជាមួយអង្គការអប់រំ Los Angeles County of Education ដើម្បីផ្តល់ការបង្ហាត់ដល់ផ្ទះដល់សិស្សជាកូនចិញ្ចឹមដោយមិនគិតលុយ (មកទល់នឹងពេលនេះមានសិស្ស 280 នាក់ដែលកំពុងទទួលសេវាកម្មនេះ)
- សហការជាមួយផ្ទះសំណាក់សម្រាប់អ្នកគ្មានទីលំនៅនិងគ្រួសារយកកូនមកចិញ្ចឹមនៅ Long Beach ដើម្បីបញ្ជាក់ថាសិស្សជាកូនចិញ្ចឹមបានចុះឈ្មោះចូលសាលារៀនចាស់គេវិញឬសាលារៀនថ្មីឲ្យបានទាន់ពេលវេលា។
- បញ្ជាក់ថាអ្នកសង្គមកិច្ចរបស់សិស្សជាកូនចិញ្ចឹមមកចូលរួមប្រជុំ IEP ដើម្បីឲ្យមានអ្នកកាន់សិទ្ធិនៃការអប់រំមានវត្តមាននិងបញ្ហាផ្សេងៗត្រូវបានពិភាក្សា។
- សហការជាមួយអ្នកផ្តល់ឱវាទនិងបុគ្គលិកដ៏ទៃទៀតដើម្បីបញ្ជាក់ថាសិស្សជាកូនចិញ្ចឹមកំពុងរៀនថ្នាក់ទី១២ទាំងអស់បានដាក់ពាក្យសុំជំនួយបង់ថ្លៃដើម្បីទៅរៀននៅមហាវិទ្យាល័យឬសាកលវិទ្យាល័យ។
- ជួយអ្នកផ្តល់ឱវាទនៅសាលាវិទ្យាល័យនិងបុគ្គលិកដ៏ទៃទៀតឲ្យចេះបំពេញក្រដាសសុំក្រេឌិត (AB 216) សម្រាប់សិស្សជាកូនចិញ្ចឹមថ្នាក់ទី១១និងទី១២ដែលបានផ្ទេរសាលាបន្ទាប់ពីបានរៀននៅសាលាវិទ្យាល័យបានពីរឆ្នាំ។
- សហការជាមួយអង្គការ Los Angeles County Department of Children and Family Services (DCFS) ដើម្បីបញ្ជាក់ថាសិស្សជាកូនចិញ្ចឹមបានទទួលសេវាសង្គមកិច្ច ផ្លូវចិត្ត និងការសិក្សា។

## បង្កើនឬធ្វើឲ្យប្រសើរឡើងដល់សេវាកម្ម

បើមិនទាន់បានពិភាក្សាមកហើយទេ ស្វែងរកមើលរបៀបពីរទៅបីយ៉ាងដែលក្រសួងអប់រំនឹងបង្កើនឬធ្វើឲ្យប្រសើរឡើងដល់សេវាកម្មសម្រាប់សិស្សមកពីគ្រួសារក្រីក្រ អ្នករៀនភាសាអង់គ្លេស និងសិស្សជាកូនចិញ្ចឹម។

| |
|---|
| សូមមើលផ្នែក "ការពិនិត្យមើលលទ្ធផល" នៅខាងលើ |

## សេចក្តីសង្ខេបពីថវិការ

បំពេញតារាងខាងក្រោមនេះ។ ក្រសួងអប់រំអាចដាក់បញ្ចូលផងដែរនូវព័ត៌មានបន្ថែម រួមទាំងរូបតារាងក្រាហ្វជាដើម។

| ការពណ៌នា | ចំនួន |
|---|---|
| ចំនួនថវិការទូទៅដែលបានចំណាយសម្រាប់ឆ្នាំ LCAP | (Pending) |
| ចំនួនថវិការសម្រាប់ចាត់ចែងកិច្ចការរៀបចំនិងសេវាកម្មផ្សេងៗ ដើម្បីបំពេញតាមគោលដៅ LCAP សម្រាប់ឆ្នាំ LCAP | (Pending) |

ឯកសារ LCAP គឺសម្រាប់ជាគំរូរៀបចំគ្រោងដែលអាចមិនមានពណ៌នាចំណាយថវិការទូទៅទាំងអស់ទេ។ ការពណ៌នាជាសង្ខេបនៃថវិការចំណាយទូទៅដែលបានរាយរាប់ខាងលើសម្រាប់ឆ្នាំ LCAP មិនបានដាក់បញ្ចូលក្នុង LCAP ទេ។

| |
|---|
| ដោយឡែកពីការចែកចាយសម្រាប់ការគាំទ្រដល់ការអប់រំពិសេស LCAP នេះពុំមានរាយរាប់ពីចំណាយផ្សេងៗលើកម្មវិធីពិសេសទេ។ |

| | |
|---|---|
| (Pending) | ចំនួនថវិការស្មានទាំងអស់សម្រាប់ប្រើនៅឆ្នាំ LCAP |